ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងផែនការ

លេខ :..........✓..................

# សេចក្ដីប្រកាសព័ត៌មាន

## ស្ដីពី

## ការផ្លាស់ប្ដូរឆ្នាំគោលគណនេយ្យជាតិពីឆ្នាំ២០០០ ទៅឆ្នាំ២០១៤

ក្រសួងផែនការ មានសេចក្ដីសោមនស្សរីករាយសូមជម្រាបជូនសាធារណជន អ្នកប្រើប្រាស់ទិន្នន័យស្ថិតិ អ្នកសារព័ត៌មាន អ្នកសិក្សាស្រាវជ្រាវ ស្ដីអំពីការបិទបញ្ចប់ការងារផ្លាស់ប្ដូរឆ្នាំគោលគណនេយ្យជាតិពីឆ្នាំគោល២០០០ ទៅឆ្នាំគោល២០១៤។ ក្រសួងផែនការបានសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំសិក្ខាសាលាប្រកាសផ្សព្វផ្សាយលទ្ធផលការផ្លាស់ប្ដូរឆ្នាំគោលគណនេយ្យជាតិពីឆ្នាំ២០០០ ទៅឆ្នាំ២០១៤ ក្រោមអធិបតីភាពឯកឧត្ដម **ប៊ិន ត្រាឈៃ** រដ្ឋមន្ត្រីក្រសួងផែនការ នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៤ នៅសណ្ឋាគារសុខាភ្នំពេញ។ ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) គឺជាការគណនាតម្លៃជារូបិយវត្ថុ នៃផលិតផល និងសេវាកម្មសម្រេចសរុប របស់ប្រទេសមួយតាមថ្លៃទីផ្សារក្នុងមួយឆ្នាំ។

ឆ្នាំគោលគណនេយ្យជាតិ ឬឆ្នាំគោល ផ.ស.ស. គឺជាដំណើរការនៃការជំនួសឡើងវិញឆ្នាំគោលចាស់ (ឆ្នាំ២០០០) ដែលបានប្រើប្រាស់សម្រាប់ចងក្រង ផ.ស.ស. ជាងម្ភៃឆ្នាំមកហើយ ជាមួយនឹងឆ្នាំគោលថ្មី (ឆ្នាំ២០១៤) ដើម្បីធ្វើការគណនាថ្លៃថេរ ផ.ស.ស. សម្រាប់វាស់វែងទំហំនិងកំណើនសេដ្ឋកិច្ច។ ក្នុងរយៈពេលមួយដ៏វែងនេះ សេដ្ឋកិច្ចកម្ពុជាមានការប្រែប្រួលថ្លៃ និងរចនាសម្ព័ន្ធ វាជាការចាំបាច់ក្នុងការផ្លាស់ប្ដូរឆ្នាំគោលថ្មី ជាបន្តបន្ទាប់ដើម្បីឆ្លើយតបទៅនឹងប្រែប្រួលនេះ ដើម្បីលើកកម្ពស់គុណភាព និងរបាយការណ៍ ផ.ស.ស.។ តាមអនុសាសន៍របស់នាយកដ្ឋានស្ថិតិអង្គការសហប្រជាជាតិ (UN Statistics Department-UNSD) និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ស្នើឱ្យប្រទេសជាសមាជិកផ្លាស់ប្ដូរឆ្នាំគោល ផ.ស.ស. រៀងរាល់៥ឆ្នាំ ឬយូរបំផុត១០ឆ្នាំម្ដង។

ការងារផ្លាស់ប្ដូរឆ្នាំគោល ផ.ស.ស. ឆ្នាំ២០១៤ មានរយៈពេលជាង២ឆ្នាំ ចាប់ផ្ដើមនាចុងឆ្នាំ២០១៧ និងបានបញ្ចប់នាចុងខែធ្នូ ឆ្នាំ២០១៩ ក្រោមជំនួយបច្ចេកទេសពីគណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក(UNESCAP) និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍

អន្តរជាតិស៊ុយអែត(SIDA) ដែលបានចាត់បញ្ជូនអ្នកជំនាញស្ថិតិគណនេយ្យជាតិពីស្ថាប័នស្ថិតិចក្រភពអង់គ្លេស (ONS-UK) និងស្ថាប័នស្ថិតិប្រទេសស៊ុយអែត(SCB) មកដឹកនាំមន្ត្រីនាយកដ្ឋានគណនេយ្យជាតិនៃវិទ្យាស្ថានជាតិស្ថិតិរបស់ក្រសួងផែនការដោយផ្ទាល់ និងបានចាត់អ្នកសេដ្ឋកិច្ចជាន់ខ្ពស់ពីស្ថាប័នស្ថិតិប្រទេសស៊ុយអែត(SCB) មកជួយពិនិត្យលទ្ធផល។

ការផ្លាស់ប្តូរឆ្នាំគោល ផ.ស.ស. ឆ្នាំ២០១៤ បានផ្អែកលើប្រភពទិន្នន័យសំខាន់ៗ រួមមាន៖ ជំរឿនសេដ្ឋកិច្ចឆ្នាំ២០១១ ជំរឿនកសិកម្មឆ្នាំ២០១៣ អង្កេតពាក់កណ្តាលជំរឿនសេដ្ឋកិច្ចឆ្នាំ២០១៤ អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១៤ និងប្រភពទិន្នន័យរដ្ឋបាលផ្សេងទៀត ដូចជា ជញ្ជីងទូទាត់ (ធនាគារជាតិនៃកម្ពុជា) ស្ថិតិហិរញ្ញវត្ថុរាជរដ្ឋាភិបាល(ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ទិន្នន័យពាណិជ្ជកម្មអន្តរជាតិ (អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា) និងទិន្នន័យក្រសួង ស្ថាប័នផ្សេងទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា។

លទ្ធផលបឋមការផ្លាស់ប្តូរឆ្នាំគោល ផ.ស.ស. ឆ្នាំ២០១៤ ត្រូវបានត្រួតពិនិត្យគុណភាព និងពិភាក្សាជាច្រើនលើកជាមួយអ្នកជំនាញនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា មូលនិធិរូបិយវត្ថុអន្តរជាតិ និងស្ថាប័នស្ថិតិប្រទេសស៊ុយអែត រហូតលទ្ធផលចុងក្រោយសម្រេចបាន ដូចមានចំណុចសង្ខេបសំខាន់ៗខាងក្រោម៖

១- ទំហំសេដ្ឋកិច្ច ៨៨,៩ ទ្រីលានរៀល ស្មើនឹង ២២,១ ប៊ីលានដុល្លារអាម៉េរិក នៅឆ្នាំគោល២០១៤ បើធៀបនឹងឆ្នាំ២០០០ មានទំហំសេដ្ឋកិច្ច ៦៧,៤ទ្រីលានរៀល បានកើនឡើង ៣១,៩%។

២- រចនាសម្ព័ន្ធសេដ្ឋកិច្ច៖ វិស័យកសិកម្មមានចំណែក ២២% នៃ ផ.ស.ស. (ថយចុះពី ២៩%) វិស័យឧស្សាហកម្មមានចំណែក ៣០% នៃ ផ.ស.ស. (កើនពី ២៦%) វិស័យសេវាកម្មមានចំណែក ៤២% នៃ ផ.ស.ស. (កើនពី ៤០%) នៅឆ្នាំ២០១៤ បើធៀបនឹងឆ្នាំ២០០០ ។

៣- ចំណូលសម្រាប់ម្នាក់ (GDP per capita) កើនពី ១ ១៣១ ដុល្លារអាម៉េរិក ដល់ ១ ៤៨៩ ដុល្លារអាម៉េរិក នៅឆ្នាំ២០១៤។

៤- គិតក្នុងឆ្នាំ២០២២ សេដ្ឋកិច្ចកម្ពុជាមានទំហំ ១៦០,១ ទ្រីលានរៀលតាមថ្លៃបច្ចុប្បន្ន ស្មើនឹង ៣៩,៥ ប៊ីលានដុល្លារអាម៉េរិក និងកំណើន ៥,១%។ ចំណូលសម្រាប់ម្នាក់ ប៉ាន់ស្មាន ២ ៣៤៥ ដុល្លារអាម៉េរិក។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន អ្នកប្រើប្រាស់ទិន្នន័យស្ថិតិ អ្នកសារព័ត៌មាន អ្នកសិក្សាស្រាវជ្រាវ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ១១រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងផែនការ